កិច្ចការ២៥:១៣-២៦:៣

## ព្រះរាជាអ័គ្រីប៉ា
## និងព្រះនាងបេរេនីសមកជួបលោកភេស្ទុស

**ក្រោយបួនដប់ថ្ងៃមកទៀត ព្រះរាជាអ័គ្រីប៉ា នឹងព្រះនាងបេរេនីស ស្ដេចយាងចុះមកឯសេសារា ក៏ចូលទៅសួរលោកភេស្ទុស (កិច្ចការ២៥:១៣)។**

លោកភេស្ទុស ព្រះរាជាអ័គ្រីប៉ា និងព្រះនាងបេរេនីស សុទ្ធតែជាសមាជិកគណបក្សនយោបាយដែលកាន់អំណាចជាមួយគ្នា។ ដូច្នេះ អ្នកទាំងពីរមានភាពស្និទ្ធស្នាលជាមួយគ្នាណាស់ ក្នុងការដឹកនាំនយោបាយក្នុងខេត្តយូដាទាំងមូល។

**[១៤] កាលទ្រង់គង់នៅទីនោះជាយូរថ្ងៃ នោះលោកភេស្ទុសក៏ទូលពី**
**រឿងប៉ុល ថ្វាយស្ដេចថា លោកភេលីចបានទុកអ្នកទោសម្នាក់ ឱ្យ**
**ជាប់គុកនៅទីនេះ [១៥] ហើយកាលដែលទូលបង្គំនៅក្រុងយេរូសា**
**ឡិម នោះពួកសង្គ្រាជ នឹងពួកចាស់ទុំនៃសាសន៍យូដា បានប្ដឹង**

**ទូលបង្គំ ទាំងសូមឱ្យទូលបង្គំកាត់ទោសឱ្យ (កិច្ចការ២៥:១៤-១៥)។**

លុះដល់លោកអភិបាលខេត្ត និងព្រះរាជាអស់រឿងនិយាយ លោកក៏នាំគ្នាដំណាលអំពីរឿងរបស់សាវ័កប៉ុល។

**តែទូលបង្គំឆ្លើយប្រាប់គេថា សាសន៍រ៉ូមមិនដែលបញ្ជូនមនុស្សណាឱ្យត្រូវស្លាប់ មុនដែលចុងចំឡើយមានពួកដើមចោទនៅមុខខ្លួន ហើយមានឱកាសនឹងដោះសាពីរឿងគេចោទនោះឡើយ (កិច្ចការ ២៥:១៦)។**

យើងឃើញនៅក្នុងការកាត់ទោសដល់ព្រះអម្ចាស់យេស៊ូវ និងការកាត់ទោសដល់សាវ័កប៉ុល ប្រព័ន្ធតុលាការសាសន៍រ៉ូមដែលគេជឿថា ជាប្រព័ន្ធដែលមានយុត្តិធម៌ជាទីបំផុត មានអំពើអយុត្តិធម៌ដែរ។ ប៉ុន្តែ អំពើអយុត្តិធម៌នោះ មិនមែនកើតមកពីច្បាប់ទេ គឺកើតមកពីអ្នកនយោបាយ ដែលមិនព្រមយកច្បាប់មកអនុវត្ត។ សព្វថ្ងៃប្រព័ន្ធតុលាការនៅក្នុងសកលលោក ប្រើប្រព័ន្ធតុលាការរបស់សាសន៍រ៉ូម។ ប្រព័ន្ធច្បាប់តុលាការរបស់សាសន៍រ៉ូម នៅតែមានប្រសិទ្ធភាពមកទល់ពេលសព្វថ្ងៃនេះ បើអ្នកនយោបាយមានសុឆន្ទៈនឹងយកច្បាប់មកដាក់អោយខ្ពស់ជាងមាគ៌ានយោបាយរបស់ខ្លួន។

**[១៧]ដូច្នេះ កាលគេបានមកទីនេះ នោះដល់ថ្ងៃស្អែកឡើង ទូលបង្គំ
បានអង្គុយនៅទីជំនុំជំរះក្តី ដោយឥតបង្អង់ហើយក៏បង្គាប់ឱ្យនាំ
មនុស្សនោះមក [១៨]តែកាលពួកដើមចោទបានឈរឡើង គេមិន
បានចោទប្រកាន់វាអំពីរឿងអ្វី ឱ្យដូចដែលទូលបង្គំបានស្មាននោះ
ទេ [១៩]គេគ្រាន់តែប្រកាន់ពីរបៀបសាសនាគេ ហើយពីដំណើរម្នាក់
ឈ្មោះយេស៊ូវ ដែលស្លាប់ទៅហើយ តែប៉ុលប្រកាន់ថា នៅរស់
នៅប៉ុណ្ណោះ (កិច្ចការ២៥:១៧-១៩)។**

ពេលគេហៅលោកមកនិយាយ សាវ័កប៉ុលលើកយកបញ្ហាព្រះយេស៊ូវគ្រីស្ទរស់ពីសុគតឡើងវិញ យកមកនិយាយតែម្តង។ សាវ័កប៉ុលធ្វើបន្ទាល់នៅមុខចៅហ្វាយខេត្តភេស្ទុសថា លោកមានទោសដោយសារលោកជឿថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទរស់ពីសុគតឡើងវិញ។

**[២០]ហើយដែលទូលបង្គំទ័លគំនិតនឹងពិចារណាពីសេចក្តីនោះ ក៏សួរ
វា បើវាសុខចិត្តនឹងទៅឯក្រុងយេរូសាឡិម ឱ្យបានជំនុំជំរះពីរឿង
នោះឬទេ [២១]តែវាបានសូមរើក្តីដល់មហារាជអូគូស្ទ ឱ្យបានជ្រាប
វិញ បានជាទូលបង្គំបង្គាប់ឱ្យឃុំទុកសិន ទំរាំតែទូលបង្គំមាន
ឱកាសនឹងបញ្ជូនទៅឯសេសារ [២២]ព្រះរាជាអគ្រីប៉ាមានបន្ទូល**

**ទៅលោកភេស្ទុសថា ខ្ញុំក៏ចង់ស្ដាប់អ្នកនោះដែរ លោកទូលឆ្លើយថា ស្អែកនេះទ្រង់នឹងបានស្ដាប់វាហើយ (កិច្ចការ២៥:២០-២២)។**

លោកអភិបាលខេត្តភេស្ទុស មិនដឹងជាសម្រេចយ៉ាងណាពីការសូមស្នើរើក្ដីរបស់សាវ័កប៉ុលទៅដល់ព្រះរាជាសេសារនៅទីក្រុងរ៉ូម។ ដូច្នេះហើយ បានជាលោកទូលសូមយោបល់អំពីព្រះរាជាអ័គ្រីប៉ា។ ព្រះរាជាអ័គ្រីប៉ាក៏ធ្លាប់ឮរឿងសាវ័កប៉ុលល្បៀងៗដែរ។ ដូច្នេះ ព្រះរាជចង់ស្ដាប់សាច់រឿងរបស់សាវ័កប៉ុលដោយផ្ទាល់ត្រចៀក។ មន្ត្រីជាន់ខ្ពស់ទាំងពីររូប បានរៀបចំដំណើរសាវ័កប៉ុល ដើម្បីបញ្ជូនទៅទីក្រុងរ៉ូម។ លោកទាំងពីរធ្វើការនេះ ដោយមិនបានដឹងថា ព្រះជាម្ចាស់មានផែនការបែបនោះទេ។ ព្រះជាម្ចាស់បើកសម្តែងអោយសាវ័កប៉ុលដឹងថា លោកត្រូវទៅទីក្រុងរ៉ូម។ ឥឡូវលោកបានធ្វើដំណើរទៅទីក្រុងរ៉ូម ដូចព្រះអម្ចាស់មានបន្ទូលមកមែន។

## សាវ័កប៉ុលធ្វើបន្ទាល់នៅមុខលោកភេស្ទុស និងព្រះរាជាអ័គ្រីប៉ា

**ដូច្នេះ លុះថ្ងៃស្អែកឡើង នោះព្រះរាជាអ័គ្រីប៉ា នឹងព្រះនាងបេរេនីស ក៏យាងមក ដោយដំណើរដ៏រុងរឿង ចូលទៅក្នុងសាលាក្តី មានទាំងមេទ័ពធំ នឹងពួកអ្នកធំក្នុងទីក្រុងផង រួចកាលលោកភេស្ទុសបានបង្គាប់ហើយ នោះគេនាំប៉ុលចូលមក (កិច្ចការ ២៥:២៣)។**

ព្រះរាជាអ័គ្រីប៉ា គឺជាក្សត្រមួយអង្គដែលគ្រងរាជ្យនៅក្នុងចក្រភពរ៉ូម ក្រោមមហារាជ្យសេសារអូគូស្ត។ ក្សត្រអង្គនេះ មានអំណាចខ្លាំងណាស់ នៅទឹកដីមជ្ឈឹមបូព៌ា។ សាវ័កប៉ុលបានអធិប្បាយថ្វាយព្រះរាជាអ័គ្រីប៉ា។ កន្លងមកតើមានគ្រូអធិប្បាយណាអាចផ្សព្វផ្សាយព្រះបន្ទូលអោយក្សត្រធំ ដូចជាព្រះរាជាអ័គ្រីប៉ាស្តាប់ព្រះបន្ទូលដែរឬទេ? គ្មានទេ! នៅពេលណាក្សត្រគ្រងរាជ្យយាងទៅទីណាម្តងៗ ទ្រង់មិនដែលយាងដោយទៅមួយអង្គទ្រង់ឡើយ។ ទ្រង់តែងតែយាងទៅជាមួយនឹងមន្ត្រីធំតូច អ្នកមុខអ្នកការ ព្រមទាំងអង្គរក្សការពារជាច្រើនសិបនាក់។ ពិធីទទួលព្រះរាជាអ័គ្រីប៉ាយាងទៅស្តាប់ទីបន្ទាល់របស់សាវ័កប៉ុល មានលក្ខណៈអធិកអធ័មជាទីបំផុត។ លុះព្រះរាជានិងមន្ត្រីតូចធំ ព្រមទាំងអ្នកមុខអ្នកការគ្រប់រូប ដែលចាំបាច់ត្រូវចូលមកទីប្រជុំ បានរកកន្លែងគួរសមរៀងខ្លួនហើយ គេក៏បង្គាប់អោយនាំសាវ័កប៉ុលមកឈរពីមុខអ្នកស្តាប់ទាំងនោះ។ លោកអភិបាលខេត្តភេស្ទុសទូលសូមស្នើយោបល់ អំពីព្រះរាជាអ័គ្រីប៉ា ដើម្បីអោយទ្រង់ជួយរៀបចំកសាងសំណុំរឿង បញ្ជូនសាវ័កប៉ុលទៅថ្វាយមហារាជ

សេសារអូគូស្ទ ដើម្បីកាត់ក្ដីរឿងនោះ។

**[២៤] លោកភេស្ទុសក៏ទូលថា ឱព្រះករុណាអ័គ្រីប៉ា នឹងអស់លោក
ដែលនៅទីនេះ ជាមួយនឹងយើងខ្ញុំអើយ សូមទតមើលមនុស្សនេះ
ដែលបណ្ដាជនសាសន៍យូដាទាំងប៉ុន្មាន បានប្ដឹងដល់ទូលបង្គំ
កាលនៅឯក្រុងយេរូសាឡិម ហើយនឹងនៅទីនេះដែរ ដោយ
សំរែកថា មិនគួរឱ្យវានៅរស់ទៀតទេ [២៥] តែទូលបង្គំមិនឃើញថា
មានទោសអ្វីដែលគួរឱ្យស្លាប់សោះ ហើយដែលខ្លួនវាបានសូមរើ
ក្ដីដល់មហារាជអូគូស្ទវិញ នោះបានជាទូលបង្គំសំរេចថា នឹង
បញ្ជូនវាឱ្យទៅចុះ [២៦] តែទូលបង្គំគ្មានរឿងអ្វីជាប្រាកដ នឹងសរសេរ
ថ្វាយដល់ព្រះអម្ចាស់នៃទូលបង្គំ ពីដំណើរវាទេ ហេតុនោះបាន
ជាទូលបង្គំនាំវាមកនៅទីចំពោះមុខនៃអស់លោកទាំងឡាយ មាន
ព្រះរាជាជាដើម ឱព្រះរាជាអ័គ្រីប៉ាអើយ ដើម្បីកាលណាបាន
ពិចារណាសួរវារួចហើយ នោះទូលបង្គំនឹងបានរឿងអ្វីខ្លះ ឱ្យដាក់
ចុះក្នុងសំបុត្រ [២៧] ដ្បិតបើតាមទូលបង្គំ មើលទៅដូចជាគ្មានទំនង
នឹងបញ្ជូនអ្នកទោសទៅ ឥតមានបង្ហាញទោសទាំងប៉ុន្មាន ដែល
គេចោទដល់វានោះទេ (កិច្ចការ២៥:២៤-២៧)។**

បើតាមពាក្យបណ្តឹងរបស់លោកអភិបាលខេត្តភេស្ទុស ទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា លោកអភិបាលខេត្តរកមិនឃើញថា សាវ័កប៉ុលមានកំហុសអ្វីឡើយ។ លោកមិនមានហេតុការណ៍ណា ដែលគួរអោយបញ្ជូនសាវ័កប៉ុលទៅអោយអំពល់ដល់មហារាជសេសារអូគូស្ទទេ។ សាច់រឿងរបស់សាវ័កប៉ុល មិនស៊ីជាមួយនឹងច្បាប់រាជការរ៉ូមឡើយ។ សាវ័កប៉ុលជាមនុស្សដែលមានសេរីភាពដូចពលរដ្ឋធម្មតាដែរ បើតាមច្បាប់តុលាការរបស់រាជការរ៉ូម។ ដូច្នេះ សាវ័កប៉ុលត្រូវគេបញ្ជូនមកទីនេះ មិនមែនជាអ្នកទោសទេ ពោលគឺជាគ្រូអធិប្បាយយ៉ាងចំណានមួយរូប ដែលត្រូវផ្សព្វផ្សាយព្រះបន្ទូលដល់ពួកស្តេច និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ ត្រង់នេះ យើងឃើញច្បាស់ហើយថា ព្រះជាម្ចាស់មានបន្ទូលមកកាន់សាវ័កប៉ុល អោយលោកត្រូវធ្វើទីបន្ទាល់ពីព្រះនាមព្រះអង្គដល់ពួកស្តេចនិងពួកមន្ត្រី។ ឥឡូវហេតុការណ៍នេះ កើតឡើងដូចព្រះជាម្ចាស់មានបន្ទូលមែន។ នៅក្នុងជំពូក២៦ យើងនឹងសិក្សាលំអិតអំពីហេតុការណ៍ដែលកើតឡើងជាក់ស្តែង នៅទីជំនុំជំរះក្តី ដែលសាវ័កប៉ុលបានធ្វើទីបន្ទាល់ផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវដល់រាជការរ៉ូម។

# ជំពូក ២៦

*ផាទចនា ទីបន្ទាល់របស់សាវ័កប៉ុលទូលថ្វាយព្រះរាជាអ័គ្រីប៉ា*

សាវ័កប៉ុលបានឡើងទៅធ្វើទីបន្ទាល់នៅមុខសាលាជំនុំជំរះក្តីមែន តែលោកមិនមែនដោះសារឿងគេចោទប្រកាន់ដល់លោកទេ។ លោកដឹងថា លោកគ្មានកំហុសអ្វីឡើយ រីឯលោកអភិបាលខេត្តទាំងពីរ គឺលោកភេលីច ហើយនិងលោកភេស្ទុស ក៏រកមិនឃើញថា សាវ័កប៉ុលមានកំហុសអ្វីដែរ។ ដូច្នេះ នៅពេលសាវ័កប៉ុលឈរនៅមុខទីជំនុំជំរះ ដែលមានឥស្សរជនរាជការរ៉ូមជាច្រើនរយនាក់ អង្គុយនៅទីនោះ សាវ័កប៉ុលប្រកាសដំណឹងល្អពីព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គោលបំណងរបស់សាវ័កប៉ុលក្នុងការអធិប្បាយព្រះបន្ទូលលើកនេះ គឺចង់នាំព្រះរាជាអ័គ្រីប៉ានិងមន្ត្រីគ្រប់ជាន់ថ្នាក់របស់រាជការរ៉ូម ទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ។ ជំពូក២៦ គឺជាជំពូកដែលមានតម្លៃជាទីបំផុត ទោះក្នុងវិស័យអក្សរសីល្ប៍របស់គ្រីស្ទបរិស័ទ ក៏ដូចជាអក្សរសីល្ប៍របស់សកលលោកទាំងមូល។

ផ្នែកអក្សរសីល្ប៍ក្នុងលោក គេយល់ថា ជំពូក២៦មានតម្លៃ ពីព្រោះសិល្បករដែលល្បីល្បាញ មុននឹងចូលទៅសម្តែង គេតែងតែអោយសិល្បករគ្រប់រូបទន្ទេញរត់មាត់អោយចាំគម្ពីរកិច្ចការជំពូក២៦។ ឯខ្លឹមសារនៅក្នុងជំពូកនេះទៀតសោត គឺសម្តែងអំពីសិល្បសាស្ត្រនៃការនិយាយ ដើម្បីអោយមនុស្សដទៃទៀតយល់ព្រមតាមគំនិតដែល

អ្នកសម្តែងបានថ្លែងប្រាប់។ បើអ្នកសម្តែងទន្ទេញចាំជំពូក២៦នេះហើយ ទើបមានសមត្ថភាពចូលសម្តែងក្នុងឆាកធំៗ ដើម្បីអោយសាធារណជនគ្រប់ឋានៈបានទស្សនា។ ចំណែកខ្លឹមសារខាងព្រលឹងវិញ្ញាណវិញ នៅក្នុងជំពូក២៦ រាប់ថាជាខ្លឹមសារដែលមានតម្លៃជាទីបំផុតសម្រាប់គ្រីស្ទបរិស័ទ ពិសេសវិជ្ជាអធិប្បាយព្រះបន្ទូលព្រះ។

## ទីបន្ទាល់របស់សាវ័កប៉ុលទូល ថ្វាយព្រះរាជាអ័គ្រីប៉ា

**ព្រះរាជាអ័គ្រីប៉ាមានបន្ទូលទៅប៉ុលថា ឯងមានច្បាប់និយាយដោយខ្លួនឯងបាន រួចប៉ុលក៏លើកដៃទៅមុខដោះសាខ្លួនថា (កិច្ចការ២៦:១)។**

កិច្ចការដែលសាវ័កប៉ុលបានផ្សាយព្រះបន្ទូលថ្វាយព្រះរាជាអ័គ្រីប៉ា គឺជាកិច្ចការដែលខ្ពស់បំផុត ក្នុងកិច្ចការបម្រើព្រះអង្គ។ កិច្ចការនេះ គឺជាការសម្រេចតាមសេចក្តីទំនាយដែលថា លោកត្រូវទៅឈរនៅចំពោះពួកស្តេច និងពួកមន្ត្រី។ ហេតុការណ៍ដែលសាវ័កប៉ុលឈរនៅមុខព្រះរាជាអ័គ្រីប៉ា ជាបំណងព្រះហឫទ័យរបស់ព្រះ។ ខ្ញុំបានជម្រាបរួចម្តងមកហើយថា គម្ពីរកិច្ចការជំពូក២៦ មានឥទ្ធិពលខ្លាំងមកលើអស់

អ្នកណាដែលអានដោយយកចិត្តទុកដាក់។ បើអានរួចហើយ ពិចារណាគ្រីស្ទបរិស័ទគ្រប់រូប មានការយល់ដឹងថ្មី អំពីកិច្ចការងារដែលខ្លួនកំពុងបម្រើដល់ព្រះដ៏ខ្ពស់។

នៅក្នុងជំពូក២៦ យើងឃើញមានសេចក្តីពិតខ្លះៗ ដែលយើងត្រូវយកមកពិចារណា។ សេចក្តីទាំងនោះមានបង្កប់ទុកនៅក្នុងសេចក្តីអធិប្បាយរបស់សាវ័កប៉ុលទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា។ ទីមួយ យើងត្រូវយល់ថា នៅក្នុងពេលនេះសាវ័កប៉ុលមិនមែនឈរទទួលការជំនុំជំរះពីជនណាឡើយ។ តាមច្បាប់របស់រាជការរ៉ូម សាវ័កប៉ុលជាមនុស្សមានសេរីភាព ដូចប្រជាពលរដ្ឋធម្មតា។ សាវ័កប៉ុលមិនបានដោះសារឿងរបស់លោកនៅចំពោះមុខព្រះរាជាអ័គ្រីប៉ាទេ។ ផ្ទុយទៅវិញ លោកកំពុងអធិប្បាយព្រះបន្ទូល។ នៅពេលដែលយើងឃើញថា សាវ័កប៉ុលសូមស្នើរឿងក្តីរបស់លោក ទៅដល់មហារាជ្យសេសារអូគូស្ទ ព្រះរាជាអ័គ្រីប៉ា មិនបានបន្ទោសសាវ័កប៉ុលសូម្បីមួយម៉ាត់សោះ។ ចំណែកលោកអភិបាលខេត្តភេស្ទុស ក៏មិនរកឃើញមានកំហុសណាយកមកចោទប្រកាន់សាវ័កប៉ុលបានដែរ។ ដូច្នេះ បានជាគម្ពីរកិច្ចការជំពូក២៦:៣២ លោកលូកាបានកត់ត្រាទុកថា "ហើយស្តេចអ័គ្រីប៉ា មានបន្ទូលទៅលោកភេស្ទុសថា មនុស្សនេះបើមិនបានសូមរើក្តីដល់សេសារទេ នោះនឹងលែងបាន"។ បុគ្គលពីររូបដែលមានអំណាចក្នុងការដោះលែងសាវ័កប៉ុលចេញពីមន្ទីរឃុំឃាំង គឺព្រះរាជាអ័គ្រីប៉ា និងលោកអភិបាលខេត្តភេស្ទុស។ លោកទាំងពីរមិនមានរឿងចោទប្រកាន់ដល់សាវ័កប៉ុលឡើយ។ ប៉ុន្តែ លោកទាំងពីរមិនអាចដោះលែងសាវ័កប៉ុលអោយមានសេរីភាពរួចពីមន្ទីរឃុំឃាំងទេ។ ដូច្នេះ ក្នុងករណីនេះ អ្នកទាំងពីរគ្មានអំណាចមកលើសាវ័កប៉ុលឡើយ។ ដោយ

សារហេតុនោះហើយ បានជាសាវ៉កប៉ុលមិនចាំបាច់ដោះសារឿងគេចោទប្រកាន់លោកទេ។ ផ្ទុយទៅវិញ លោកពន្យល់ដល់អ្នកស្ដាប់ទាំងអស់ពីដំណឹងល្អ ដោយចង់នាំអ្នកទាំងនោះអោយជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ទីពីរ ព្រះជាម្ចាស់ផ្ដល់ឱកាសដល់សាវ៉កប៉ុល ដើម្បីផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះអង្គដល់រាជការរ៉ូម។ ខ្ញុំបានជម្រាបរួចមកហើយថា ព្រះរាជាអ័គ្រីប៉ាចង់ដឹងផ្ទាល់ថា តើពាក្យថា "ផ្លូវនោះ" ដែលសាវ៉កប៉ុលតែងតែអធិប្បាយនោះ មានន័យថាយ៉ាងដូចម្ដេច។ នៅក្នុងដើមសតវត្សរ៍ទីមួយ ពេលក្រុមជំនុំរបស់ព្រះយេស៊ូវទើបនឹងកកើត គេមិនហៅពួកអ្នកជឿថានៅក្នុងក្រុមនេះ ឬក្រុមនោះណាមួយទេ គេគ្រាន់តែហៅថាជាពួកដើរតាម "ផ្លូវនោះ"។ "ផ្លូវនោះ" គឺជាផ្លូវដែលព្រះអម្ចាស់យេស៊ូវមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន១៤:៦ថា "ខ្ញុំជាផ្លូវ..."។ "ផ្លូវនោះ" គឺអង្គព្រះយេស៊ូវផ្ទាល់។ កន្លងមកព្រះរាជាអ័គ្រីប៉ា ព្រមទាំងរាជការគ្រប់ជាន់ថ្នាក់ឮគេនិយាយពី "ផ្លូវនោះ" ដែលសាវ៉កប៉ុល និងពួកគ្រីស្ទាននាំគ្នាដើរប្រកាសប្រាប់អ្នកដទៃៗទៀត។ ឥឡូវ គេបានឮពាក្យ "ផ្លូវនោះ" ផ្ទាល់ចេញពីបបូរមាត់របស់សាវ៉កប៉ុល ដែលជាបាវបម្រើរបស់ព្រះដ៏ខ្ពស់បំផុត។ សាវ៉កប៉ុលឆ្លៀតឱកាសដែលមិនមានតម្លៃអ្វីមកប្រៀបផ្ទឹមបាន សម្ដែងពីព្រះអម្ចាស់យេស៊ូវអោយរាជការរ៉ូមគ្រប់ជាន់ថ្នាក់ស្ដាប់ អោយយល់ពីអត្ថន័យនៃពាក្យ "ផ្លូវនោះ"។

សូមយើងសង្កេតមើលអំពីពិធីយាងស្ដេចអ័គ្រីប៉ាចូលក្នុងរោងជំនុំ ដោយមានក្បួនដង្ហែរយ៉ាងអធិកអធម និងមានសណ្ដាប់ធ្នាប់រៀបរយជាទីបំផុត តាមពិធីការ

របស់រាជការរ៉ូម ជាអ្នកគ្រប់គ្រងសកលលោកទាំងមូល។ ចាប់តាំងពីពេលព្រលឹម យើងឃើញមានទាហានពាក់ឯកសណ្ឋានសព្រោងព្រាតឈរតំរង់ជួរ ដោយមានឧបករណ៍ភ្លេងកាន់គ្រប់ដៃ។ នៅពីមុខកងទាហានទាំងនោះ មានអ្នកកាន់ទង់ ដើម្បីបញ្ជាក្រុមទាហានសម្រាប់ពិធីបដិសណ្ឋារកិច្ច។ មេទ័ព ទាហាន និងក្រសួងមានសមត្ថកិច្ចរៀបចំសន្តិសុខយ៉ាងរៀបរយ និងមានសណ្តាប់ធ្នាប់។ គេក្រាលព្រំក្រហម ព្រមទាំងតុបតែងផ្កាភ្ញីយ៉ាងល្អនៅតុមុខកៅអីដែលព្រះរាជាអ័គ្រីប៉ា ត្រូវយាងមកគង់។ នៅជួរខាងក្រោយព្រះរាជាអ័គ្រីប៉ា មានកៅអីសម្រាប់ឥស្សរជនជាន់ខ្ពស់ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ ឥឡូវដល់ពេលព្រះរាជាអ័គ្រីប៉ាយាងចូលរោងជំនុំហើយ។ ព្រះរាជាអ័គ្រីប៉ាយាងចូលមកជាមួយនឹងព្រះជាយារបស់ទ្រង់នាមនាងបេរេនីស។ ពីក្រោយទ្រង់មានឥស្សរជនជាន់ខ្ពស់ជាច្រើនរូបអមដំណើរព្រះរាជា។ លុះទ្រង់យាងចូលមក គេក៏បន្លឺសម្លេងផ្លុំត្រែ ព្រមទាំងភ្លេងទទួលទ្រង់។ លុះទ្រង់គង់តាមកន្លែងរបស់ទ្រង់ និងឥស្សរជនដទៃទៀត អង្គុយតាមកន្លែងរបស់លោក គេនាំគ្នាគោរពភ្លេងជាតិ។ ការប្រជុំគ្នានេះ មានលក្ខណៈអធិកអធ័មខ្លាំងណាស់ ពីព្រោះក្នុងសម័យនោះ រាជការរ៉ូមជាអ្នកគ្រប់គ្រងផែនដីទាំងមូល។

លុះពិធីបដិសណ្ឋារកិច្ចបានចប់សព្វគ្រប់ហើយ លោកអភិបាលខេត្តឡើងថ្លែងការណ៍ជម្រាបអ្នកស្តាប់ទាំងអស់អំពីមូលហេតុដែលគេត្រូវជួបជុំគ្នានៅក្នុងថ្ងៃនេះ។ តើហេតុអ្វីបានជាគេនាំគ្នាមកយ៉ាងអធិកអធ័មដូច្នេះ? បណ្ឌិតលូកាកត់ត្រារឿងនេះប្រាប់យើងថា "ដូច្នេះ លុះថ្ងៃស្អែកឡើង នោះព្រះរាជាអ័គ្រីប៉ា នឹងព្រះនាងបេរេនីសក៏យាង

មកដោយដំណើរដ៏រុងរឿង ចូលទៅក្នុងសាលាក្តី មានទាំងមេទ័ពធំនឹងពួកអ្នកធំក្នុងទីក្រុងផង រួចកាលលោកភេស្ទុសបានបង្គាប់ហើយ នោះគេនាំប៉ុលចូលមក" (កិច្ចការ២៥:២៣)។

មូលហេតុដែលព្រះរាជា អ្នកមុខអ្នកការ ឥស្សរជនគ្រប់គ្រងនៅភូមិភាគនោះ ចូលមកជួបជុំគ្នានៅថ្ងៃនេះ ដើម្បីស្តាប់ការអធិប្បាយរបស់សាវ័កប៉ុល។ គេនាំគ្នាធ្វើបដិសណ្ឋារកិច្ចយ៉ាងគគ្រឹកគគ្រេង ពីព្រោះគេចង់ស្តាប់អ្នកទោសម្នាក់នាមសាវ័កប៉ុល និយាយប្រាប់រឿងរបស់លោកជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាវ័កប៉ុលធ្លាប់ធ្វើដំណើរក្នុងចក្រភពរ៉ូម ជាពិសេសភូមិភាគខាងកើត ដើម្បីអធិប្បាយប្រាប់មនុស្សលោកអំពី "ផ្លូវនោះ"។

លុះលោកភេស្ទុសជាអភិបាលខេត្ត បានបញ្ជាដល់កងតម្រួត។ ឯទ្វារក៏បើកឡើង រួចយើងឃើញអ្នកទោសម្នាក់ ដែលដាក់ច្រវាក់ចេញមក។ សំលៀកបំពាក់របស់លោក ជាសំលៀកបំពាក់អ្នកទោស។ លោកត្រូវគេភ្ជាប់ច្រវាក់ដៃឆ្វេងជាមួយនឹងអ្នកយាមមួយរូប ដៃស្តាំជាមួយអ្នកយាមមួយរូបទៀត។ រូបរាងរបស់សាវ័កប៉ុល មើលទៅមិនសមជាគ្រូអធិប្បាយដ៏ល្បីល្បាញនោះទេ។ សាវ័កប៉ុល គឺជាបុរសម្នាក់ ដែលបង្រៀនព្រមទាំងអធិប្បាយអំពីសេចក្តីសុគត ការបញ្ចុះទៅក្នុងផ្នូរ និងការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវ។ លោកអធិប្បាយប្រាប់មនុស្សលោកថា មនុស្សគ្រប់រូបជាមនុស្សមានបាប ត្រូវការអង្គព្រះយេស៊ូវជាអង្គសង្គ្រោះផ្ទាល់ខ្លួន។ លោកគឺជាបុរសម្នាក់ដែលមានអំណាចក្នុងការបង្ហាត់បង្រៀនពី "ផ្លូវនោះ"។ ព្រះរាជាអ័គ្រីប៉ា និងរាជការរ៉ូមទាំងអស់

នាំគ្នាស្ដាប់សាវ័កប៉ុលដោយយកចិត្តទុកដាក់ ពីព្រោះគេធ្លាប់ស្គាល់លោកថាជាអ្នកប្រាជ្ញមួយរូបដែរ។ ពន្លឺនៃស្ថានសួគ៌ចាំងចែងពេញផ្ទៃមុខរបស់លោក។ លោកលែងមានឈ្មោះថាសូល ពីស្រុកតើសុសទៀតហើយ គឺលោកមានឈ្មោះថា លោកប៉ុល ជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវ។ សាវ័កប៉ុល ទោះបីលោកជាអ្នកប្រាជ្ញក៏ដោយ លោកមានលក្ខណៈខុសអំពីមនុស្សដែលអង្គុយស្ដាប់លោកទាំងអម្បាលមាណ។

ទីបី គេនាំសាវ័កប៉ុលមកទីនេះ ដោយមានការច្រណែនឈ្នានីស។ គេស្អប់សាវ័កប៉ុលណាស់ បានជាចោទលោកទាំងបំពាន ព្រមទាំងចាប់លោកយកមកដាក់ទីឃុំឃាំងដោយអយុត្តិធម៌ផង។ មនុស្សម្នានាំគ្នាសម្លឹងមើលលោកប៉ុល ហើយសាវ័កប៉ុលក៏សម្លឹងមើលទៅកាន់មនុស្សដែលអង្គុយរង់ចាំស្ដាប់លោកដែរ។ ខ្ញុំជឿថា ក្នុងពេលនោះមានមនុស្សខ្លះលាន់មាត់ថា អ្នកប្រាជ្ញមួយរូបនេះមិនគួរក្លាយទៅជាអ្នកទោសយ៉ាងដូច្នេះសោះ។ អ្នកខ្លះទៀតនិយាយថា គាត់រូបរាងយ៉ាងដូច្នេះសោះ ហេតុអ្វីបានជាអធិប្បាយមានអំណាចខ្លាំងម្ល៉េះ។ អ្នកខ្លះនិយាយទៀតថា លោកនេះសមជាអ្នកដទៃស្អប់ហើយ។ ប៉ុន្តែសូមកុំភ្លេចព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវដែរបានសន្យារួចហើយថា "បើសិនជាលោកីយស្អប់អ្នករាល់គ្នា នោះអ្នករាល់គ្នាដឹងហើយ ថាគេបានស្អប់ខ្ញុំជាមុន" (យ៉ូហាន១៥:១៨)។ សាវ័កប៉ុលពិតជាសិស្សរបស់ព្រះអម្ចាស់យេស៊ូវមែន បានជាមនុស្សរបស់លោកីយ៍ស្អប់លោកខ្លាំងណាស់។

បើតាមយើងយល់ សាវ័កប៉ុលមិនមានរូបរាងស្អាតបាតខ្ពស់ស្រឡះ ដែលធ្វើអោយអ្នកផងចាប់ចិត្តនោះទេ។ ព្រះគុណរបស់ព្រះជាម្ចាស់ដែលសណ្ឋិតនៅលើ

លោក ធ្វើអោយមនុស្សដទៃៗទៀត ចាប់ភ្ជឹកជាមួយនឹងលោកយ៉ាងខ្លាំង។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបានបញ្ចេញចេស្តារបស់ទ្រង់ ក្នុងរូបកាយរបស់សាវ័កប៉ុល។ ដូច្នេះហើយបានជាលោកអ្នកហើយនិងខ្ញុំ មានសិទ្ធិធ្វើការប្រកាសរួមជាមួយសាវ័កប៉ុលថា "ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែ ខ្ញុំរស់នៅមិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ស្រឡាញ់ខ្ញុំក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ" (កាឡាទី២:២០)។

ទីបួន សូមយើងសង្កេតមើលអំពីលក្ខណៈផ្ទុយគ្នា រវាងសាវ័កប៉ុលនិងព្រះរាជាអ័គ្រីប៉ា។ សាវ័កប៉ុល គឺជាអ្នកទោស រីឯព្រះរាជាអ័គ្រីប៉ាវិញ គឺជាក្សត្រគ្រងរាជ្យ ដែលទ្រង់ព្រះពស្ត្រសំពត់ពណ៌ស្វាយ។ ព្រះរាជាអ័គ្រីប៉ា គឺជាក្សត្រគ្រងរាជ្យមានពេញដោយចេស្តា ឯសាវ័កប៉ុលវិញ គឺជាអ្នកទោសដែលជាប់ច្រវាក់។ ព្រះរាជាអ័គ្រីប៉ាពាក់មកុដ សាវ័កប៉ុលពាក់អាវអ្នកទោស។ អ័គ្រីប៉ាជាក្សត្រគ្រងរាជ្យ ប៉ុន្តែជាបាវបម្រើរបស់អំពើបាប។ សាវ័កប៉ុលជាអ្នកជាប់ច្រវាក់ តែមានសេរីភាព ព្រោះព្រះជាម្ចាស់បានអត់ទោសដល់លោកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវហើយ។ ព្រះរាជាអ័គ្រីប៉ា គឺជាស្តេចនៃផែនដី ដែលមិនអាចរំដោះខ្លួនលោកផ្ទាល់អោយចេញពីអំពើបាប ក៏មិនអាចដោះសាវ័កប៉ុល អោយរួចពីការចោទប្រកាន់បាន។ ចំណែកឯសាវ័កប៉ុលវិញ គឺជារាជទូតនៃព្រះដ៏ខ្ពស់ដ៏បំផុត ដែលដោះសាវ័កប៉ុលអោយមានសេរីភាព។ ព្រះអង្គនេះអាចដោះព្រះរាជាអ័គ្រីប៉ា អោយរួចពីខ្នោះកំដររបស់អំពើបាបដែរ បើក្សត្រអង្គនេះ ព្រម

ប្រគល់ព្រះទ័យរបស់ទ្រង់ថ្វាយដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ខ្ញុំចង់ជម្រាបដល់លោកអ្នកបងប្អូនបន្តិចអំពីសាវរតារបស់ព្រះរាជាអ័គ្រីប៉ា។ ព្រះរាជាអ័គ្រីប៉ា ត្រូវជាសមាជិកគ្រួសាររបស់ស្តេចហេរ៉ូឌ។ ដូចយើងបានរៀនពីបទគម្ពីរមុនៗរួចមកហើយថា ស្តេចហេរ៉ូឌជាគ្រួសារដែលកាចសាហាវជាងគ្រួសារណាៗទាំងអស់ ដែលធ្លាប់រស់នៅលើលោកនេះ។ គម្ពីរបានសម្តែងអំពីកិរិយាអាក្រក់របស់គ្រួសារស្តេចអង្គនេះ។ នៅក្នុងគម្ពីរសញ្ញាចាស់ មានក្សត្រមួយអង្គនាមអ័ហាប់ និងភរិយារបស់ទ្រង់ឈ្មោះយេសិបិល។ ស្តេចអង្គនេះនិងជាយាមានកិរិយាអាក្រក់ជួរជាតិខុសអំពីស្តេចនានាដែលធ្លាប់សោយរាជ្យនៅលើផែនដី។ ប៉ុន្តែ បើប្រៀបធៀបស្តេចអង្គខាងលើទៅនឹងសមាជិកគ្រួសារស្តេចហេរ៉ូឌ អំពើអាក្រក់របស់ស្តេចអ័ហាប់ និងជាយាស្មើនឹងកូនង៉ែតរបស់គ្រួសារហេរ៉ូឌប៉ុណ្ណោះ។ គ្រួសារហេរ៉ូឌជាគ្រួសារដែលប្រគល់ខ្លួនប្រាណនិងចិត្តអោយសាតាំងប្រើប្រាស់ទាំងស្រុងតែម្តង។ ព្រះរាជាអ័គ្រីប៉ា ថ្វីដ្បិតស្ថិតនៅក្នុងត្រកូលស្តេចហេរ៉ូឌ តែលោកជាមនុស្សដែលមានប្រាជ្ញាវាងវៃណាស់។ លោកស្គាល់ច្បាប់របស់លោកម៉ូសេ ព្រមទាំងចូលចិត្តនិយាយអំពីសាសនាយូដា។ សាវ៉កប៉ុលមានចិត្តរីករាយដែលបានមានឱកាសទូលថ្វាយរឿង ដល់ព្រះរាជាអ័គ្រីប៉ា ពីព្រោះស្តេចអង្គនេះយល់អំពីពាក្យចោទប្រកាន់ទាំងអម្បាលមាណហើយ។

ខ្ញុំជឿថា សាវ៉កប៉ុលមានការពិបាកក្នុងចិត្តខ្លះៗដែរ ពីព្រោះអស់រយៈពេលពីរឆ្នាំហើយ ដែលលោកមិនអាចធ្វើអ្វីបាន ទោះបីលោកជាមនុស្សគ្មានទោសតាមច្បាប់តុលាការរបស់រាជការរ៉ូមក៏ដោយ។ កន្លងមកលោកបានពន្យល់រឿងរបស់លោកដល់

ក្រុមបាតុករនៅក្នុងទីក្រុងយេរូសាឡិម។ បន្ទាប់មកទៀត លោកពន្យល់រឿងក្ដីនោះ ដល់មេទ័ព ព្រមទាំងដល់លោកអភិបាលខេត្តភេលីច ទាំងក្នុងទីសាធារណៈ ទាំងជួបផ្ទាល់ជាមួយនឹងមន្ត្រីរូបនេះជាច្រើនលើកជាច្រើនសារ។ បន្ទាប់ពីនោះមក លោកត្រូវជួបជាមួយនឹងលោកអភិបាលខេត្តភេស្ទុស។ ឥឡូវលោកត្រូវជួបជាមួយនឹងព្រះរាជាអ័គ្រីប៉ាទៀត។ អស់រយៈពេលពីរឆ្នាំ ឥស្សរជនជាន់ខ្ពស់របស់រាជការរ៉ូម មិនអាចរកកំហុសអ្វីមួយចោទប្រកាន់ដល់សាវ័កប៉ុល អោយត្រូវតាមផ្លូវច្បាប់បានទេ។ ម្យ៉ាងទៀត អ្នកដែលស្ដាប់សាវ័កប៉ុលទាំងអម្បាលមាណ ក៏មិនបានយល់ច្បាស់អំពីដំណឹងល្អ ដែលសាវ័កប៉ុលបានផ្សព្វផ្សាយដែរ។ រឿងនេះ កើតឡើងនៅទីក្រុងយេរូសាឡិម ក៏ដូចជាកើតឡើងនៅទីក្រុងរ៉ូម។ យើងមានការភ្ញាក់ផ្អើលខ្លាំងណាស់ ពីព្រោះមនុស្សដែលរស់នៅក្នុងភូមិសាស្ត្រមានពួកគ្រីស្ទានអធិប្បាយព្រះបន្ទូលរបស់ព្រះអង្គយ៉ាងសុសសាយ ប៉ុន្តែ គេនៅតែមិនយល់អំពីដំណើរដែលព្រះយេស៊ូវយាងមកសុគត និងរស់ឡើងវិញជំនួសគេ។ មនុស្សលោកតាំងពីសម័យដើម មកទល់សម័យឥឡូវនេះ នៅមិនទាន់មានការប្ដូរផ្លាស់ក្នុងករណីមួយនេះទេ។

លុះសាវ័កប៉ុលពន្យល់អស់អាថ៌សេចក្ដីហើយ លោកក៏សូមយាងព្រះរាជាអ័គ្រីប៉ាអោយទទួលជឿព្រះអម្ចាស់យេស៊ូវ។ ការទទូចអង្វរដែលសាវ័កប៉ុលទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា គឺជាជំហានធំបំផុត ដែលសាវ័កប៉ុលចង់នាំទ្រង់ថ្វាយព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**២ បពិត្រព្រះករុណាអ័គ្រីប៉ាអើយ នៅថ្ងៃនេះ ទូលបង្គំមានចិត្ត
អំណរណាស់ ដោយមានច្បាប់នឹងដោះសាខ្លួននៅចំពោះទ្រង់ ពី
អស់ទាំងសេចក្តីដែលសាសន៍យូដាចោទប្រកាន់ទូលបង្គំ ៣ គឺពី
ព្រោះទ្រង់ជ្រាបគ្រប់ទាំងទំលាប់ នឹងសេចក្តីជជែករបស់ពួក
សាសន៍យូដាជាដើម ដូច្នេះ ទូលបង្គំសូមអង្វរ ឲ្យព្រះករុណាទ្រង់
ព្រះសណ្តាប់ទូលបង្គំ ដោយអំណត់សិន (កិច្ចការ២៦:២–៣)។**

សាវ័កប៉ុលកំពុងនិយាយទៅកាន់បុរសម្នាក់ ដែលយល់អំពីសាច់រឿងដែលលោកកំពុងនិយាយ។ ព្រះរាជាអ័គ្រីប៉ា គឺជាក្សត្រមួយអង្គដែលមានប្រាជ្ញាវាងវៃណាស់។ ព្រះអង្គស្គាល់ច្បាប់របស់លោកម៉ូសេ ព្រមទាំងទំនៀមទម្លាប់របស់សាសន៍យូដាយ៉ាងច្បាស់លាស់។ សាវ័កប៉ុលរីករាយនឹងពន្យល់ដល់ព្រះរាជាអង្គនេះ ពីអង្គព្រះយេស៊ូវ។ សាវ័កប៉ុលពន្យល់ថា ច្បាប់ទម្លាប់របស់លោកម៉ូសេល្អឥតខ្ចោះ ប៉ុន្តែមនុស្សមិនអាចកាន់បានទេ។ កន្លងមកលោកក៏ជាអ្នកកាន់ច្បាប់លោកម៉ូសេដែរ។ លុះដល់សាវ័កប៉ុលជួបជាមួយនឹងព្រះអម្ចាស់យេស៊ូវ ច្បាប់របស់លោកម៉ូសេមានខ្លឹមសារយ៉ាងជ្រាលជ្រៅជាងការលោកមិនទាន់ស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រលឹងរបស់សាវ័កប៉ុល ជួបជាមួយនឹងពន្លឺយ៉ាងត្រចះត្រចង់ ព្រោះលោកបានស្គាល់សេចក្តីសុចរិតក្នុងព្រះអម្ចាស់យេស៊ូវ។ សាវ័កប៉ុលដឹងថា ព្រះជាម្ចាស់ចង់អោយមនុស្សលោករស់ដោយសុចរិត ប៉ុន្តែមនុស្សមិនអាចរស់នៅតាមសេចក្តីបង្គាប់របស់ព្រះជាម្ចាស់បាន។ ព្រះជាម្ចាស់

ប្រទានព្រះរាជបុត្រានាមព្រះយេស៊ូវ ដើម្បីអោយមកសុគតជំនួសមនុស្សលោក ដើម្បីផ្តល់សេចក្តីសុគតិតដល់អស់អ្នកណាដែលជឿដល់ព្រះអង្គ។ សាវ័កប៉ុលចង់អោយព្រះរាជាអ័គ្រីប៉ាជ្រាបពីដំណឹងល្អនេះ។ ព្រះរាជាអ័គ្រីប៉ាស្តាប់រឿងនោះ ដោយជក់ចិត្តជាទីបំផុត។

នៅក្នុងចំណោមពួកអ្នកស្តាប់មានមនុស្សប្រមាណរាប់រយនាក់ ប៉ុន្តែ សាវ័កប៉ុលទូលថ្វាយសំដៅទៅកាន់តែមនុស្សម្នាក់ គឺព្រះរាជាអ័គ្រីប៉ា។ សាវ័កប៉ុលចង់នាំព្រះរាជាអ័គ្រីប៉ាថ្វាយព្រះអម្ចាស់យេស៊ូវ។

នៅពេលសាវ័កប៉ុលចាប់ផ្តើមមានប្រសាសន៍ លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាថា លោកអរគុណដល់ព្រះរាជា ដោយបានផ្តល់ឱកាសដល់លោក។ រួចហើយលោកពន្យល់អំពីប្រវត្តិរូបរបស់លោកបន្តិចអំពីកាលលោកនៅក្មេង ព្រមទាំងកាលលោកបានទទួលនាទីជាអ្នកធ្វើទុក្ខបុកម្នេញដល់ពួកជំនុំ។ ក្រោយមកទៀត លោកពន្យល់ស្តេចអ័គ្រីប៉ា អំពីការប្រែចិត្តរបស់លោកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ទីបំផុតលោកសួរបញ្ជាក់ដល់ព្រះរាជាអ័គ្រីប៉ា យ៉ាងស្តេចអង្គនេះអោយទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ឯសេចក្តីអធិប្បាយរបស់សាវ័កប៉ុល ដោយពិស្តារនោះ យើងនឹងអានជូននៅពេលក្រោយ។

យើងស្វែះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"